ក្រសួងធនធានទឹក និងឧតុនិយម

# សេចក្តីជូនដំណឹង
# ស្តីពីការព្យាករអាកាសធាតុលើកទី២
# សម្រាប់រដូវវស្សាចាប់ពីខែកក្កដា ដល់ខែតុលា ឆ្នាំ២០២៦

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបពីស្ថានភាពអាកាសធាតុនៅក្នុងរដូវវស្សាឆ្នាំ២០២៦ ដូចខាងក្រោម៖

I- **បាតុភូតសកល**

យោងទៅលើការព្យាករស្តីពីស្ថានភាពវិវត្តន៍នៃសីតុណ្ហភាពនៅលើផ្ទៃមហាសមុទ្រប៉ាស៊ីហ្វិកខាងលិច មហាសមុទ្រឥណ្ឌា និងតំបន់អេក្វាទ័របង្ហាញឱ្យឃើញថា៖

**១-បាតុភូត អែលនីញ៉ូ** (El Niño) បានបន្តកើនដល់កម្រិត ១០០% ក្នុងខែកក្កដា និងកើនដល់កម្រិតអតិបរមាក្នុងខែវិច្ឆិកា ឆ្នាំ២០២៦។

**២-បាតុភូត អាយ អូ ឌី** (IOD) ស្ថិតនៅអព្យាក្រឹត(IOD-Neutral)។

ស្ថានភាពបែបនេះនឹងធ្វើឱ្យចាប់ពីពាក់កណ្តាលរដូវវស្សា ដល់ចុងរដូវវស្សា ឆ្នាំ២០២៦៖

II- **រដូវវស្សា**

**រដូវវស្សា៖** ចាប់ពាក់កណ្តាលរដូវវស្សាពីខែកក្កដា ដល់ខែសីហា កូនរដូវប្រាំងនឹងចាប់ផ្តើមនៅក្នុងសប្តាហ៍ទី១ នៃខែសីហា ឆ្នាំ២០២៦ និងលឿនជាងឆ្នាំ២០២៥ ដែលអាចមានរយៈពេលពីរសប្តាហ៍។ សីតុណ្ហភាពមធ្យមអប្បបរមា ២៦°C និងអតិបរមា ៣៧°C ខ្ពស់ជាងសីតុណ្ហភាពមធ្យមភាគច្រើនឆ្នាំ និងខ្ពស់ជាងឆ្នាំ២០២៥។

**១. ពាក់កណ្តាលរដូវវស្សា៖**

**១.១.សីតុណ្ហភាព៖** សីតុណ្ហភាពមធ្យមអប្បបរមា និងអតិបរមា ខ្ពស់ជាងមធ្យមភាគច្រើនឆ្នាំ។

**១.២.បរិមាណទឹកភ្លៀង៖** នៅខែកក្កដា ដល់ខែសីហា ទឹកភ្លៀងមានកម្ពស់ខ្ពស់ជាងមធ្យមភាគច្រើនឆ្នាំ។ បរិមាណទឹកភ្លៀងមានពីបង្គួរទៅច្រើន។

**២. ចុងរដូវវស្សា៖**

**២.១.សីតុណ្ហភាព៖** សីតុណ្ហភាពមធ្យមអប្បបរមា និងអតិបរមា ទាបជាងមធ្យមភាគច្រើនឆ្នាំ។

**២.២.បរិមាណទឹកភ្លៀង៖** នៅខែកញ្ញា ដល់ខែតុលា មរិមាណទឹកភ្លៀងទាបជាងឬប្រហាក់ប្រហែលនឹងមធ្យមភាគច្រើនឆ្នាំ និងបរិមាណទឹកភ្លៀងពីច្រើនទៅមធ្យម។

III- **ជាសរុបរដូវវស្សា** ចាប់ពីពាក់កណ្តាលរដូវវស្សារហូតបញ្ចប់រដូវវស្សាឆ្នាំ២០២៦ សីតុណ្ហភាពមធ្យមអប្បបរមា ២៦°C និងអតិបរមា ៣៧°C ខ្ពស់ជាងសីតុណ្ហភាពមធ្យមភាគច្រើនឆ្នាំ និងខ្ពស់ជាងឆ្នាំ២០២៥។ បរិមាណទឹកភ្លៀងប្រហាក់ប្រហែលនឹងមធ្យមភាគច្រើនឆ្នាំ ជាមួយនឹងរបាយទឹកភ្លៀងធ្លាក់រាយប៉ាយបានល្អដូចឆ្នាំ២០២៥។

# អគារលេខ: ៣៦៤ មហាវិថី ព្រះមុនីវង្ស សង្កាត់ ផ្សារដើមថ្កូវ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១៦ ៦៧០
#364, Monivong BLVD, Phsar Deumthkov, Chamkarmon, Phnom Penh, Cambodia, Phone: (855)23 216 670

បាតុភូតផ្គរ រន្ទះ និងខ្យល់កន្ត្រាក់អាចកើតឡើងច្រើន ប៉ុន្តែនៅចុងរដូវវស្សាបរិមាណទឹកភ្លៀងថយចុះ ហើយរដូវវស្សាអាចបញ្ចប់នៅក្នុងសប្តាហ៍ទី២ នៃខែតុលា ដែលលឿនជាងធម្មតា និងឆ្នាំ២០២៥។

យោងលើការព្យាករអាកាសធាតុដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបជាព័ត៌មាន។ ក្រសួងធនធានទឹក និងឧតុនិយម សូមជូនដំណឹងដល់ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងប្រជាពលរដ្ឋ សូមយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នចំពោះអាកាសធាតុដែលមានបាតុភូតផ្គរ រន្ទះ និងខ្យល់កន្ត្រាក់ដែលអាចកើតមានច្រើននៅក្នុងឆ្នាំ២០២៦ និងចាត់វិធានការរក្សាទឹកឱ្យបានច្រើននៅពាក់កណ្តាល និងចុងរដូវវស្សានេះ ដើម្បីត្រៀមបង្ការការខ្វះខាតទឹកនៅរដូវប្រាំងខាងមុខ៕

ថ្ងៃអង្គារ ២កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៦